**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

លេខ ៧៥៤ សទណ.អគទ

ថ្ងៃព្រហស្បតិ៍ ១០កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០២០

# សេចក្ដីជូនដំណឹង

## វេទិកាទេសចរណ៍អាស៊ាន ២០២១ (ATF 2021) ត្រូវលើកពេលទៅ ឆ្នាំ២០២២ វិញ ក្រោមប្រធានបទ "អាស៊ាន៖ សហគមន៍សន្តិភាព និងវាសនារួមគ្នា"

ក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជាមានកិត្តិយស និងក្ដីសោមនស្ស សូមជម្រាបជូនស្ថាប័នពាក់ព័ន្ធ ប្រតិបត្តិករទេសចរណ៍ ដៃគូអភិវឌ្ឍន៍ បណ្ដាញផ្សព្វផ្សាយ និងសាធារណជនឱ្យបានជ្រាបថា ដោយសារជំងឺរាតត្បាត COVID-19 នាពេលបច្ចុប្បន្នដែលបង្កការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរចំពោះវិស័យទេសចរណ៍ និងភាពមិនច្បាស់លាស់អំពីពេលវេលានៃការបញ្ចប់ជំងឺដ៏សាហាវនេះ ក្រសួងទេសចរណ៍ ក្នុងនាមជាម្ចាស់ផ្ទះវេទិកាទេសចរណ៍អាស៊ាន ២០២១ បានធ្វើការស្ទាបស្ទង់មតិអំពីការលើកពេលនៃការរៀបចំវេទិកានេះទៅឆ្នាំ២០២២ វិញ តាមរយៈការប្រជុំ Online ជាមួយប្រទេសជាសមាជិក ពិសេសបានធ្វើការយ៉ាងជិតស្និទ្ធជាមួយស្ថានទូតឥណ្ឌូនេស៊ីប្រចាំកម្ពុជា និង ក្រសួងទេសចរណ៍និងច្នៃប្រឌិតសេដ្ឋកិច្ចឥណ្ឌូនេស៊ី ដែលជាម្ចាស់ផ្ទះវេទិកាទេសចរណ៍អាស៊ានបន្ទាប់សម្រាប់គាំទ្រការលើកវេនខាងលើ។

តាមរយៈលិខិតយោងលេខ B/PP.02.00/1138/S/2020 ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០ របស់ក្រសួងទេសចរណ៍និងច្នៃប្រឌិតសេដ្ឋកិច្ចឥណ្ឌូនេស៊ី និងលិខិតយោងលេខ ៩៨៣ សជណ.ពទ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងទេសចរណ៍ សូមជូនដំណឹងដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ឱ្យបានជ្រាបថា **កម្ពុជានឹងធ្វើជាម្ចាស់ផ្ទះវេទិកាទេសចរណ៍អាស៊ាន២០២២វិញ** ដែលមានទាំងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី NTOs និងឯកជន រួមទាំងព្រឹត្តិការណ៍តាំងពិព័រណ៍ទេសចរណ៍អន្តរជាតិ (TRAVEX) ដែលមានការចូលរួមពីអ្នកទិញ-អ្នកលក់អន្តរជាតិ អ្នកលក់ក្នុងស្រុក និងអ្នកសារព័ត៌មានជាតិ-អន្តរជាតិជាច្រើន។ ដោយឡែក ក្រសួងនៅតែបន្តរៀបចំកិច្ចប្រជុំតាមរយៈ Online ដើម្បីសម្រេចឯកសារមួយចំនួនក្នុងនាមជាម្ចាស់ផ្ទះ។ សម្រាប់ព័ត៌មានស្ដីពីកាលបរិច្ឆេទជាក់លាក់នៃវេទិកាទេសចរណ៍អាស៊ាន ២០២២ នៅកម្ពុជា ក្រសួងនឹងជូនព័ត៌មាននៅពេលក្រោយ។

ព្រះរាជាណាចក្រកម្ពុជា រង់ចាំទទួលស្វាគមន៍ប្រតិភូជាតិ-អន្តរជាតិ អ្នកទិញ-អ្នកលក់អន្តរជាតិ អ្នកលក់ក្នុងស្រុក និងអ្នកសារព័ត៌មានជាតិ-អន្តរជាតិទាំងអស់ ចូលរួមក្នុង**វេទិកាទេសចរណ៍អាស៊ាន ២០២២** នៅកម្ពុជា ជាគោលដៅមានសុវត្ថិភាពសម្រាប់ទេសចរអន្តរជាតិ និងជាឱកាសសម្រាប់កម្ពុជាក្នុងការចាប់ផ្ដើមឡើងវិញនៃវិស័យទេសចរណ៍។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងនាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ក្រៅប្រទេសតាមរយៈទូរស័ព្ទលេខ: (+855) 17 938 393 ឬតាមអាសយដ្ឋានអ៊ីម៉ែល: prakvuthy1983@gmail.com ។

ក្រសួងទេសចរណ៍

Scanned with CamScanner

E-mail: admin@mot.gov.kh Website: www.tourismcambodia.org